# មេរៀនទី ១២៣៖ ព្រះយេស៊ូវប្រោសឡាសារឱ្យរស់ពីស្លាប់ឡើងវិញ

[យ៉ូហាន ១១៖១-៤៥]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/Np8WpX83K5M

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/XWY-4K44YNA

**គោលបំណង៖** ព្រះយេស៊ូវមានអំណាចលើសេចក្ដីស្លាប់។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១១៖២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ។"*

**ចំរៀង** ( *យូធូបលីង* )៖

១.នៅរស់ https://youtu.be/NGQXTg3Uogg

២.ព្រះគ្រីស្ទទ្រង់រស់ឡើងវិញ https://youtu.be/WTL3xf69YEY

៣. ខ្ញុំដឹងថា https://youtu.be/ywt-KvGIQcE

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ខ្វែងក្រឡាការ៉ូ»



សម្ភារៈដែលត្រូវការ៖ ដីស ឬហ្វឺត

១. ចែកកុមារជាពីរក្រុម ( ពួកគេអាចលេងនៅលើដីក៏បាន )

២. ជ្រើសរើសសមាជិកក្រុមណាម្នាក់មកខាងមុខ

៣. ពួកគេត្រូវប្ដូរវេនគ្នាក្នុងការគូស "X" និង "O" ហើយគ្រូត្រូវគូសបន្ទាត់ ឈរពីរ និងផ្ដេកពីរនៅលើក្ដារ ខៀន (ឬនៅលើដី )អ្នកណាដែលអាចគូសញ្ញា របស់ខ្លួនបានបីជាប់គ្នាមិនថា ជួរឈរ ជួរផ្ដេក ឬទ្រេតបាន បីមុន នោះគេនឹងឈ្នះល្បែងនេះ។

៤. បន្តលេងល្បែងនេះរហូតដល់កុមារទាំងអស់បានលេងគ្រប់ៗគ្នា។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ទោះបីជាយើងចាញ់ឬឈ្នះ យើងត្រូវការការជួយសង្គ្រោះអោយរួចពីស្លាប់។ព្រះយេស៊ូវជួយយើងពីសេចក្ដីស្លាប់ពីព្រោះទ្រង់មានអំណាចលើសេចក្ដីស្លាប់។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់ឃើញមនុស្សណាស្លាប់ហើយអាចរស់ឡើងវិញបានដែរឬទេ? តើអ្នកមានអារម្មណ៍ដូចម្ដេចនៅពេលដែលអ្នកទៅចូលរួមពិធីបុណ្យសព ហើយស្រាប់តែឃើញអ្នកដែលស្លាប់នោះងើបឈរ រួចដើរសំដៅមករកអ្នកនោះ? តើអ្នកសប្បាយចិត្តដែរឬទេនៅពេលបុគ្គលដែលស្លាប់នោះរស់ឡើងវិញ? តើអ្នកខ្លាចទេបើសិនជាគេនោះជាខ្មោច? ថ្ងៃនេះ ពួកយើងនឹងរៀនអំពីរបៀបដែលព្រះយេស៊ូវបានប្រោសបុរសម្នាក់ឱ្យរស់ពីស្លាប់ឡើងវិញ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានបុរសម្នាក់ឈ្មោះឡាសាររស់នៅក្នុងភូមិបេថានី ដែលគាត់មានជំងឺជាទម្ងន់។ មារា និង ម៉ាថា ដែលត្រូវជាបងស្រីទាំងពីររបស់ឡាសារ បានផ្ដល់ដំណឹងទៅកាន់ព្រះយេស៊ូវថាឡាសាកំពុងតែមានជម្ងឺ។ នេះគឺដោយព្រោះថាព្រះយេស៊ូវគឺជាមិត្តសម្លាញ់របស់ពួកគេ ពួកគេដឹងច្បាស់ថាព្រះយេស៊ូវនឹងយាងមក ហើយនឹងជួយព្យាបាលឡាសារឱ្យបានជា។

ប៉ុន្តែនៅពេលដែលព្រះយេស៊ូវបានឮថាឡាសារឈឺ ទ្រង់បានមានបន្ទូលថា "ជម្ងឺរបស់ឡាសានឹងមិនធ្វើឱ្យគាត់ស្លាប់នោះឡើយ ប៉ុន្តែជាការថ្វាយកិត្តិស័ព្ទដល់ព្រះវិញ មនុស្សនឹងដឹងថាខ្ញុំជាព្រះរាជបុត្រានៃព្រះ។" ព្រះយេស៊ូវគង់នៅកន្លែងដដែល ២ ថ្ងៃទៀតដោយទ្រង់មិនបានយាងទៅភូមិបេថានីឡើយ។

ពីរថ្ងៃក្រោយមក ព្រះយេស៊ូវបានមានបន្ទូលទៅពួកសិស្សថា "តោះ! យើងទៅភូមិបេថានី និងទៅមើល ឡាសារជាសំឡាញ់យើង គាត់បានដេកលក់ទៅហើយ" ។ ពួកសិស្សបាននិយាយថា ពួកគេមិនចាំបាច់ ទៅនោះទេ ពីព្រោះឡាសានឹងធូរស្បើយឡើងវិញ បើសិនជាគេគ្រាន់តែដេកលក់នោះ។ ប៉ុន្តែ ព្រះយេស៊ូវ ទ្រង់មានបន្ទូលថា "ឡាសារបានស្លាប់ហើយ! នេះគឺជាពេលវេលាដ៏ល្អមួយដើម្បីឱ្យអ្នករាល់ គ្នាជឿលើខ្ញុំ។ ឥលូវចូរយើងទៅឯគាត់ចុះ។"

នៅពេលដែលព្រះយេស៊ូវទៅដល់ភូមិបេថានី មានគេប្រាប់ទ្រង់ថា ឡាសារបានស្លាប់អស់រយៈពេល ៤ ថ្ងៃហើយ។ ម៉ារា និង ម៉ាថាបានបន្ទោសព្រះយេស៊ូវថា ព្រះអម្ចាស់អើយ បើសិនជាទ្រង់បានគង់នៅទីនេះ នោះប្អូនខ្ញុំម្ចាស់មិនបានស្លាប់ទេ។ ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ប្អូននាងនឹងរស់ឡើងវិញ។ ប៉ុន្តែនាងគិតថាទ្រង់មានបន្ទូលពីការរស់ឡើងវិញនៅថ្ងៃចុងក្រោយទៅវិញ។ ព្រះយេស៊ូវមានបន្ទូលទៀត ថា **យ៉ូហាន ១១:២៥-២៦** "ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ។"

ព្រះយេស៊ូវបានយាងទៅកាន់ផ្ទះរបស់ឡាសារ។ មានមនុស្សជាច្រើននៅទីនោះ។ ព្រះយេស៊ូបឃើញម នុស្សគ្រប់គ្នាកំពុងយំ ដោយព្រោះគេស្រឡាញ់ឡាសារណាស់ ហើយព្រះយេស៊ូវក៏ទ្រង់ព្រះកន្សែង(យំ) ដែរ។ បន្ទាប់មកព្រះយេស៊ូវបានប្រាប់ឱ្យគេយកថ្មចេញ ប៉ុន្តែម៉ាថាបាននិយាយថា ខ្មោចនេះធុំក្លិនហើយ ព្រោះស្លាប់កន្លងមកបាន៤ថ្ងៃហើយ! ប៉ុន្តែព្រះយេស៊ូវនៅតែទទូចឱ្យយកថ្មចេញ។ ដើម្បីរមៀលថ្មចេញត្រូវការកម្លាំងមនុស្សច្រើននាក់។

ព្រះយេស៊ូវត្រូវបានគេឮថាទ្រង់មានបន្ទូលទៅកាន់ព្រះជាម្ចាស់ បន្ទាប់មកទ្រង់មានបន្ទូលឮៗថា "ឡាសារអើយ ចូរចេញមក" ហ្វូងមនុស្សមានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលពួកគេឃើញមនុស្សស្លាប់មានទាំងសំពត់ស្នបរុំជាប់នៅជើងដៃផង ហើយត្រូវបានគេបញ្ចុះទៅហើយ អាចដើរចេញមកខាងក្រៅផ្នូរ បាន! មានមនុស្សជាច្រើនបានជឿលើព្រះយេស៊ូវ ពីព្រោះទ្រង់បានបង្ហាញព្រះចេស្តាទ្រង់-គឺមានអំណាចឈ្នះលើសេចក្ដីស្លាប់!

យើងបានរៀនពីសាច់រឿងរបស់ឡាសារថា ព្រះយេស៊ូវមានអំណាចលើការស្លាប់ខាងឯរូបកាយ។ ព្រះគម្ពីរក៏បានប្រាប់យើងដែរថា ព្រះយេស៊ូវទ្រង់មានអំណាចលើសេចក្ដីស្លាប់ខាងឯព្រលឹងវិញ្ញាណផងដែរ។ មនុស្សដែលស្លាប់ខាងឯព្រលឹងវិញ្ញាណគឺដោយព្រោះអំពើបាបនៅក្នុងជីវិតរបស់ពួកគេ។ ព្រះគម្ពីរក៏បានប្រាប់ផងដែរថាព្រះយេស៊ូវបានសុគតដោយព្រោះអំពើបាបរបស់យើង។ ទ្រង់រងទុក្ខជំនួសយើង។ នៅពេលដែលយើងជឿ និងដាក់សេចក្តីជំនឿរបស់យើងទៅលើទ្រង់ ព្រះយេស៊ូវនឹងយាងមកក្នុងជីវិតរបស់ យើង ហើយជីវិតខាងឯព្រលឹងវិញ្ញាណរបស់យើងក៏រស់ឡើងវិញផងដែរ។ ព្រះយេស៊ូវមានអំណាច! ទ្រង់មានអំណាចលើសេចក្តីស្លាប់!

## ៦. សំនួរពិភាក្សា

១. តើបុរសម្នាក់ដែលបានស្លាប់នោះមានឈ្មោះអ្វី? *(ឡាសារ)*

២.ហេតុអ្វីព្រះយេស៊ូវមិនយាងទៅមើលគាត់ភ្លាម នៅពេលដែលទ្រង់បានឮដំណឹងថាបុរសម្នាក់នោះឈឺ?
*(ពីព្រោះព្រះយេស៊ូវជ្រាបថា ព្រះមានផែនការធំជាងនេះ ដើម្បីនឹងធ្វើឱ្យបុរសម្នាក់នោះមានជីវិតឡើងវិញ ដូច្នេះហើយទើបព្រះអង្គរង់ចាំសិន)*

៣. ហេតុអ្វីបានជាម៉ាថាព្យាយាមបញ្ឈប់ព្រះយេស៊ូវកុំឱ្យទ្រង់ប្រមៀលថ្មចេញពីផ្នូរ? *(ពីព្រោះនាងខ្លាចធុំក្លិនសព ពីព្រោះឡាសារបានស្លាប់ ៤ ថ្ងៃហើយ)*

៤. តើព្រះយេស៊ូវធ្វើឱ្យឡាសាររស់ឡើងវិញដោយរបៀបណា? *(ទ្រង់បានហៅគាត់ឱ្យដើរចេញពីក្នុងផ្នូរមក)*

៥. តើយើងអាចជួយអ្នកដែលស្លាប់ខាងឯព្រលឹងវិញ្ញាណបានដោយរបៀបណា? (*ជួយឱ្យពួកគេបានជឿថាព្រះយេស៊ូវបានស្លាប់ជំនួសបាបរបស់ពួកគេ*)
៦. តើអ្នកជឿថាព្រះយេស៊ូវមានអំណាចលើសេចក្តីស្លាប់មែនដែរឬទេ? (*សូមឱ្យកុមារជាអ្នកឆ្លើយ*)

## ៧. ល្បែងកំសាន្ត «ឈើឆ្កាងនៃព្រះ»




សម្ភារៈដែលត្រូវការ៖ រូបឈើឆ្កាង
១. ឲ្យរូបឈើឆ្កាងប្រាំទៅកុមារគ្រប់គ្នា។
២. ពួកគេត្រូវប៉ាវជាមួយកុមារផ្សេងទៀត ប្រសិនបើគេប៉ាវឈ្នះ គេត្រូវយករូបឈើឆ្កា ងមួយពីកុមារដែលប៉ាវចាញ់នោះ។
៣. កុមារណាដែលអាចប៉ាវឈ្នះហើយមានរូបឈើឆ្កាងបាន ចំនួន ១២ មុនគេនោះកុមារនោះជាអ្នកឈ្នះ
៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ឈើឆ្កាងគឺគ្រាន់តែតំណាងឲ្យព្រះតែប៉ុណ្ណោះតែសេចក្តីជំនឿរបស់យើងនោះវិញទេ ដែលអាចជួយឲ្យឈ្នះសេចក្តីស្លាប់ និងទទួលបានជីវិតអស់ កល្បជានិច្ច។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១១៖២៥** "ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយ ជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ។"

## ៩. ហត្ថកម្ម «ឡាសារនៅក្នុងប្រអប់»

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្មនៅទំព័រខាងក្រោម, កូល័រ, និងកន្ត្រៃ



១. ផាត់ពណ៌រូបភាពនៅក្នុងប្រអប់និងកាត់តាមគម្រូបន្ទាត់ចេញ។ សូមកាត់រូបភាពរបស់ឡាសារផងដែរ
២. សូមបត់ក្រដាសប្រអប់ដែលបានកាត់ចេញនោះ និងបិទភ្ជាប់គ្នាឱ្យចេញជាប្រអប់ និង ដាក់រូបឡាសារនៅក្នុងប្រអប់នោះ
៣. សូមប្រើប្រអប់ឡាសារដែលបានធ្វើរួចនោះ ដើម្បីនិទានរឿងពីព្រះយេស៊ូវប្រោសឡាសារឱ្យ រស់ឡើងវិញ៖
- ជ្រុងទី១-ព្រះយេស៊ូវគឺជាមិត្តភក្តិរបស់ម៉ារា,ម៉ាថា និង ឡាសារ
- ជ្រុងទី២-អ្នកនាំដំណឹងម្នាក់បានមកប្រាប់ព្រះយេស៊ូវថាឡាសារឈឺធ្ងន់ណាស់
- ជ្រុងទី៣-៣ ថ្ងៃក្រោយមក ព្រះយេស៊ូវបានធ្វើដំណើរទៅមើលឡាសារ
- ជ្រុងទី៤-ម៉ាថាកំពុងយំ ហើយទូលព្រះយេស៊ូវថាឡាសារបានស្លាប់ហើយ
- ជ្រុងទី៥-ព្រះយេស៊ូវកើតទុក្ខដោយសារមិត្តរបស់ទ្រង់កំពុងមានទុក្ខ។ ព្រះយេស៊ូវបានហៅឡាសារឱ្យចេញមកក្រៅ ហើយគាត់ក៏បានរស់ឡើងវិញ (សូមបើកប្រអប់ហើយទាញយករូបភាពរបស់ឡាសារចេញក្រៅ)
- ជ្រុងទី៦-ម៉ារា និងម៉ាថាសប្បាយចិត្តដោយឡាសារបានរស់ឡើងវិញ។

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកធ្លាប់មានអារម្មណ៍ថាអ្នកនៅមានជីវិត ប៉ុន្តែវាហាក់ដូចជាអ្នកមិនបានរស់នៅឬរីកចម្រើនដែរឬទេ? បន្ទាប់មកអ្នកអាចយល់ពីអារម្មណ៍នៃការអស់សង្ឃឹមដូចជា "ការស្លាប់" នៅខាងក្នុងអ៊ីចឹង។ ប៉ុន្តែព្រះយេស៊ូវបានធ្វើឲ្យមនុស្សអាចរកឃើញជីវិតនិងសេចក្តីសង្ឃឹមថ្មី ទោះជាគេមានអារម្មណ៍ថាធ្លាក់ចុះប៉ុណ្ណាក៏ដោយ។ តាមរយៈការអស្ចារ្យនៃការប្រោសឡាសារឲ្យរស់ឡើងវិញ ព្រះយេស៊ូវបានបង្ហាញថាទ្រង់អាចផ្លាស់ប្តូរយើងបាន។ ទ្រង់អាចនាំយើងត្រឡប់ពីភាពអស់សង្ឃឹម និងការអស់សង្ឃឹមត្រលប់មកវិញ។ សូមធ្វើការពិចារណាពីអំណោយរបស់ព្រះយេស៊ូវគឺជាជីវិតអស់កល្ប ដែលទ្រង់អាចផ្លាស់ប្រែ អ្នក និងសូមចំណាយពេលដើម្បីអរព្រះគុណទ្រង់សម្រាប់ការនេះ។



# ឡាសារនៅក្នុងប្រអប់




ការប្រើប្រាស់ប្រអប់ឡាសារ៖

ដាក់ពណ៌រូបភាពនៅក្នុងប្រអប់និងកាត់តាមគម្រូបន្ទាត់ចេញ។ សូមកាត់រូបភាពរបស់ឡាសារផងដែរ សូមបត់ក្រដាសប្រអប់ដែលបានកាត់ចេញនោះ និងបិទភ្ជាប់គ្នាឱ្យចេញជាប្រអប់ និង ដាក់រូបឡាសារនៅក្នុងប្រអប់នោះ នោះ សូមប្រើប្រអប់ឡាសារដែលបានធ្វើរួចនោះ ដើម្បីនិទានរឿងពីព្រះយេស៊ូវប្រោសឡាសារឱ្យ រស់ឡើងវិញ៖

ទី១: ព្រះយេស៊ូវគឺជាមិត្តភក្តិរបស់ម៉ារា,ម៉ាថា និងឡាសារ

ទី២: បុរសម្នាក់បានមកប្រាប់ព្រះយេស៊ូវថាឡាសារឈឺធ្ងន់

ទី៣: ៣ ថ្ងៃក្រោយមក ព្រះយេស៊ូវបានធ្វើដំណើរទៅមើលឡាសារ

ទី៤: ម៉ាថាកំពុងយំ ហើយទូលព្រះយេស៊ូវថាឡាសារបានស្លាប់ហើយ

ទី៥: ព្រះយេស៊ូវកើតទុក្ខដោយសារមិត្តរបស់ទ្រង់កំពុងមានទុក្ខ។ ព្រះយេស៊ូវបានហៅឡាសារឱ្យចេញមកហើយគាត់បានរស់ឡើងវិញ (សូមបើកប្រអប់ហើយយករូបភាពរបស់ឡាសារចេញមកក្រៅ)

ទី៦: ម៉ារា និងម៉ាថាសប្បាយចិត្តដោយឡាសារបានរស់ឡើងវិញ